# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៩៤៧ អនក្រ.បក

## អនុក្រឹត្យ

**ស្តីពីនីតិវិធីនៃការបើកផ្តល់មុន ដោយអាណត្តិបើកប្រាក់**

**សំរាប់**

- **ចំណាយដំណើរការរៀបចំការបោះឆ្នោតរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**
- **ចំណាយមូលនិធិសំរាប់ជួសជុលផ្លូវថ្នល់**
- **ចំណាយសំរាប់កម្មវិធីអភិវឌ្ឍន៍សុខាភិបាលស្រុកប្រតិបត្តិឈានមុខ (ADD) និង ចំណាយសំរាប់កម្មវិធីសកម្មភាពជាអាទិភាព (PAP)**

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃ ព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រម នស/រកម/០១៩៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រម ០១/នស/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ហើយត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ១១នស/៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបាន កែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខ នស/រកម/១២៩៩/១៥ ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩

-បានឃើញព្រះរាជក្រម នស/រកម/១២០០/១២ ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ២០០១

-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៨/០៤ ចុះថ្ងៃទី ២០ ខែ មិនា ឆ្នាំ ១៩៩៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតគណនីពិសេសរបស់រតនាគារជាតិ សំរាប់ការបោះឆ្នោតជ្រើសតាំង តំណាងរាស្ត្រ

-បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ

-បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុ លើការចំណាយថវិការដ្ឋនៅតាមក្រសួង ស្ថាប័ន ខេត្ត-ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល

-បានឃើញអនុក្រឹត្យលេខ ៦០ អនក្រ.បក ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ១៩៩៩ ស្តីពីការគ្រប់គ្រងលទ្ធកម្មសាធារណៈ

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សម្រេច

**មាត្រា១:** -អនុក្រឹត្យនេះមានគោលបំណងកែសម្រួលនីតិវិធីនិងបែបបទបញ្ចេញអាណត្តិបើកប្រាក់សំរាប់ :

- ចំណាយដំណើរការរៀបចំការបោះឆ្នោតរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- ចំណាយមូលនិធិសំរាប់ជួសជុលថែទាំផ្លូវថ្នល់
- ចំណាយសំរាប់កម្មវិធីអភិវឌ្ឍន៍សុខាភិបាលស្រុកប្រតិបត្តិឈានមុខ (ADD)

និងចំណាយ សំរាប់កម្មវិធីសកម្មភាពជាអាទិភាព (PAP) ។

គោលដៅនៃកិច្ចប្រតិបត្តិការនេះ គឺ ដើម្បីធានាសម្រេចបាននូវប្រសិទ្ធភាពចំណាយដល់កិច្ចការទាំងបីខាងលើ សំខាន់ធានានូវភាពទៀងទាត់ និងទាន់ពេលវេលា ។

**មាត្រា២:** -ដោយបដិប្បញ្ញត្តិ ទៅនឹងមាត្រា ៨ នៃអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ និងមាត្រា ៩ នៃអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋនៅតាមក្រសួង ស្ថាប័ន ខេត្ត-ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល រាល់ការបើកផ្តល់មុនសំរាប់មុខសញ្ញាចំណាយទាំងឡាយដែលមានចែងនៅក្នុងមាត្រា ៣ ខាងក្រោម ត្រូវធ្វើឡើងដោយអាណត្តិបើកប្រាក់ ដោយគ្រាន់តែភ្ជាប់ជាមួយនូវគំរោងចំណាយលំអិត ។

**មាត្រា៣:** -មុខសញ្ញាចំណាយដែលបើកផ្តល់មុនដោយអាណត្តិបើកប្រាក់មានដូចតទៅ :

- ចំណាយសំរាប់ការរៀបចំបោះឆ្នោតរបស់គណៈកម្មាធិការជាតិរៀបចំកាបោះឆ្នោត
- ចំណាយមូលនិធិសំរាប់ជួសជុលថែទាំផ្លូវថ្នល់
- ចំណាយសំរាប់កម្មវិធីអភិវឌ្ឍន៍សុខាភិបាលស្រុកប្រតិបត្តិឈានមុខ (ADD)

និងចំណាយសំរាប់កម្មវិធីសកម្មភាពជាអាទិភាព (PAP) ។

**មាត្រា៤:** -រាល់ចំណាយជួសជុលថែទាំ ផ្គត់ផ្គង់ទំនិញ-សេវា សំរាប់បំរើការងារដូចមានចែងក្នុងមាត្រា ៣ ខាងលើ ត្រូវអនុវត្តតាមនីតិវិធីលទ្ធកម្មសាធារណៈ ជាធរមាន ។

**មាត្រា៥:** -ក្រសួង ស្ថាប័ន ឬ អង្គភាពដែលគ្រប់គ្រងចំណាយដូចមានចែងក្នុងមាត្រា ៣ ខាងលើ ត្រូវមានភារកិច្ចធ្វើរបាយការណ៍ហិរញ្ញវត្ថុជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបន្ទាប់ពីកិច្ចប្រតិបត្តិការចំណាយលើការងារនិមួយៗត្រូវបានបញ្ចប់ ។ ក្នុងករណីមានប្រាក់នៅសល់ត្រូវបង់ចូលថវិកាជាតិវិញ ។ មុខសញ្ញាចំណាយទាំងអស់នេះ ត្រូវស្ថិតក្រោមយន្តការនៃការធ្វើសវនកម្មក្រោយចំណាយរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងអាជ្ញាធរសវនកម្មជាតិ ។

**មាត្រា៦:** -កិច្ចប្រតិបត្តិការចំណាយទាំងអស់នេះ ត្រូវមានការណែនាំអនុវត្តជាក់ស្តែងដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

**មាត្រា៧:** -រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រឹទ្ធាចារ្យប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត រដ្ឋមន្ត្រីក្រសួងសាធារណៈការនិងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ រដ្ឋមន្ត្រីក្រសួងអប់រំយុវជននិងកីឡា រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ១៤ ខែកញ្ញា ឆ្នាំ ២០០១

ហ៊ុន សែន

បានយកសេចក្តីជំរាបជូន
សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

គាត ឈន់

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**ចម្លងជូន**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- អាជ្ញាធរសវនកម្មជាតិ
- ដូចមាត្រា ៧ "ដើម្បីអនុវត្ត"

ឯកសារ កាលប្បវត្តិ